# របាយការណ៍

## វេទិកាសិក្សារៀនសូត្រការគ្រប់គ្រងហិរញ្ញវត្ថុលើកទី២២

## ស្តីពី

# ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងប្រាក់ចំណេញ

## ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨

ដាយកូនៀសិនធើ ផ្ទះលេខ១៩-២១ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ






*Prepared By: Ms. Keo Mara, Learning Specialist, CCC*

*Supported By: Mr. Sok Sovann, Mentoring and Coaching Specialist, CCC*

*Ms. Sreng Sophornlakhena, CD Assistant, CCC*

## I. សេចក្តីផ្តើម

ដើម្បីបន្តការឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់សហគមន៍អង្គការ និងពង្រឹងសមត្ថភាពបន្ថែមអំពីអភិបាលកិច្ចល្អក្នុងវិស័យអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អង្គការគសក បានបន្តអនុវត្តវេទិកាសិក្សារៀនសូត្រលើកទី២២ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ដោយផ្អែកលើប្រធាន បទដែលក្រុមការងារ និងសិក្ខាកាមដែលបានចូលរួមក្នុងវេទិកាសិក្សារៀនសូត្របានផ្តល់យោបល់ជ្រើសរើសកាលពីវេទិការៀនសូត្រកន្លងមកគឺ *"ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ* "។

វេទិកាសិក្សារៀនសូត្រលើកទី២២នៃការគ្រប់គ្រងហិរញ្ញវត្ថុគឺត្រូវបានកំណត់អ្នកចូលរួមជំនាញផ្នែកហិរញ្ញវត្ថុដែលអញ្ជើញមកពីអង្គការសមាជិក និងមិនមែនសមាជិករបស់អង្គការគសក។ វេទិកានេះបានប្រារព្ធធ្វើឡើងពេញមួយថ្ងៃនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ នៅអាគារដាយកូនៀសិនធើ ដែលមានគោលបំណងជាក់លាក់ លទ្ធផលរំពឹងទុករយៈពេលមធ្យម និងកម្មវិធីលម្អិតដូចខាងក្រោមនេះ៖

## II. គោលបំណងនៃវេទិកាសិក្សារៀនសូត្រ

- ដើម្បីជួយឲ្យសិក្ខាកាមបានយល់ច្បាស់អំពីច្បាប់ស្តីពីគណនេយ្យនិងសវនកម្មសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ
- ដើម្បីជួយឲ្យសិក្ខាកាមយល់ច្បាស់អំពីរបៀបនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុវត្តន៍តាម **"ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ"**
- ដើម្បីបង្កើតបរិយាកាសវេទិការៀនសូត្រនិងចែករំលែកក៏ដូចជាកសាងបណ្តាញឲ្យកាន់តែមានភាពរឹងមាំក្នុងចំណោមអង្គការសង្គមស៊ីវិល និងការទំនាក់ទំនងជាមួយមន្ត្រីក្រុមប្រឹក្សាជាតិគណនេយ្យឲ្យកាន់តែមានប្រសិទ្ធភាព។

## III. កិច្ចស្វាគមន៍ និង សន្ទរកថាបើកកម្មវិធី



**លោក សឿង សារឿន នាយកប្រតិបត្តិអង្គការ អង្គការ គសក** បានធ្វើការវាក្យចូដល់អង្គសិក្ខាកាមទាំងអង្គការដែលជាសមាជិក និងមិនមែនសមាជិកនៃអង្គការ គសក ដែលមានវត្តមាននៅថ្ងៃនោះ។ ជាមួយគ្នានោះផងដែរ លោកបានលើកទឹកចិត្តដល់អង្គសិក្ខាកាមទាំងអស់ថា (ប្រធានបទថ្ងៃនេះមិនមែនជាប្រធានបទថ្មីទេ) បទដ្ឋានពីរ ដែលផ្តោតនៅថ្ងៃនេះគឺ ស្តង់ដារគណនេយ្យ និងច្បាប់គ្រប់គ្រងគណនេយ្យ និងសវនកម្ម។

ច្បាប់ពិសេសសម្រាប់អង្គការមិនរកប្រាក់ចំណេញ គឺច្បាប់ស្តីពី**គណនេយ្យនិងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ** ត្រូវបានប្រកាសឲ្យប្រើប្រាស់។ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ការងារ ច្បាប់ស្តីពីរបបសន្តិសុខសង្គម ត្រូវបានអនុមតិឲ្យប្រើប្រាស់ ។ បច្ចុប្បន្នក្រុមការងារកំពុងជជែកពីច្បាប់ស្តីពីសោធននិវត្ត និងច្បាប់ពន្ធដារ ។ ក្រុមការងារបច្ចេកទេសច្បាប់ពន្ធដារ ដែលមានសមាសភាពមកពីតំណាងអង្គការសង្គមស៊ីវិលបានបានជជែកជាមួយមន្ត្រីពន្ធដារអំពីរឿងនេះ។ មន្ត្រីពន្ធដារបានមានប្រសាសន៍ថា មានប្រហែល ៦៥០ អង្គការ សមាគម បានស្នើសុំលេខសម្គាល់ពន្ធដារ។ ចំពោះអង្គការដែលមិនទាន់បានស្នើសុំលេខសំគាល់ពន្ធដារ គួរស្នើសុំឲ្យបានមុនខែធ្នូ ឆ្នាំ២០១៨ ដោយមិនមាន

ទោសឡើយ។ លោកបានលើកទឹកចិត្តដល់អង្គសិក្ខាកាមទាក់ទងមកអង្គការ គសក និងអង្គការដៃគូរ LAC, DFLD បើសិនជាត្រូវការជំនួយបច្ចេកទេសពាក់ព័ន្ធផ្លូវច្បាប់។ លោកបានបន្ថែមផងដែរថា គសក នឹងកំពុងធ្វើការជាមួយក្រសួងពាក់ព័ន្ធ ដូចជាក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងនាយកដ្ឋានពន្ធដារ ហើយគសកសជាមួយសមាជិកផងដែរដើម្បីឲ្យដឹងថាតើមានអង្គការប៉ុន្មានដែលបានស្នើសុំលេខសម្គាល់ពន្ធដារ និងមានចំនួនប៉ុន្មានអង្គការទៀតដែលមិនទាន់បានស្នើសុំលេខសម្គាល់ពន្ធដារនោះ ដើម្បីជួយសម្រួលដល់ពួកគេឲ្យបានរួចពន្ធចំណូលប្រចាំឆ្នាំ ឬសេវាកម្មផ្សេងៗទៀត ដែលការប្រកាសនិងតម្រូវដោយក្រសួង។ ក្នុងពេលនោះផងដែរ លោកបានលើកឡើង៣ចំណុចដើម្បីស្នើសុំដល់មន្ត្រីជំនាញបច្ចេកទេសៈ

1. សូមឲ្យមន្ត្រីជំនាញបច្ចេកជួយដល់អង្គការសង្គមស៊ីវិល និងគាំទ្របច្ចេកទេសរបៀបរៀបចំរបាយការណ៍តាមស្តង់ដារហិរញ្ញវត្ថុ
2. ស្នើសុំឲ្យការប្រតិបត្តិនេះជាលក្ខណ:ស្ម័គ្រចិត្ត (មិនមានទោសឬពិន័យឡើយ) ស្តង់ដាររបាយការណ៍នេះគឺប្រតិបត្តិជា cash basis ចាប់ពីពេលនេះតទៅ និង
3. ស្នើសុំឲ្យមានរបាយការណ៍តាមប្រព័ន្ធអនឡាញផងដែរ( online system)

## IV. លទ្ធផលសង្ខេបនៃវេទិកាសិក្សារៀនសូត្រ

វេទិកាសិក្សារៀនសូត្រនេះប្រារព្ធឡើងពេញមួយថ្ងៃនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ នៅអាគារដាយកូនៀសិនធើ ដែលមានអ្នកចូលរួមសរុប ២៥២នាក់ (ស្ត្រី161នាក់)ស្មើនឹង១៣៨អង្គការ ដែលក្នុងនោះរួមមាន: ៨២ INGOs, ៤៦ LNGOs, ៣ក្រុមហ៊ុនឯកជន, និង តំណាងអញ្ជើញមកពីក្រសួងសេដ្ឋកិច្ច៣រូបផងដែរ។

### <u>វគ្គទី១</u> ការរំលឹកឡើងវិញអំពីមេរៀននៃវេទិកាសិក្សារៀនសូត្រលើកមុន ស្តីពី "ការអនុវត្តច្បាប់និងពន្ធដារ" នៃព្រះរាជាណាចក្រកម្ពុជា( ដោយ លោក មាស យាង ប្រធានប្រតិបត្តិ អង្គការ CCIM)



ដើម្បីជាជំនួយស្មារតីក្នុងការចងចាំមេរៀនដែលបានរៀនកាលពីថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៨ **លោកមាស យាង ជាប្រធានប្រតិបត្តិ នៃអង្គការ** CCIM និងជាសមាជិកក្រុមការងារនៃវេទិកាសិក្សារៀនសូត្រការគ្រប់គ្រងហិរញ្ញវត្ថុ បានសង្ខេបនិងពន្យល់សិក្ខាកាមឡើងវិញនូវមេរៀន ស្តីពី "**ពន្ធដារ និងច្បាប់នៃប្រទេសកម្ពុជា**" ដោយផ្តោតលើប្រធានបទពីរគឺ"**សេចក្តីផ្តើមនៃពន្ធប្រព័ន្ធពន្ធកម្ពុជា**"និង "**កាតព្វកិច្ចសារពើពន្ធសម្រាប់អង្គការសង្គមស៊ីវិល**" ដូចដែលមានមាតិកាសំខាន់នៅក្នុងបទបង្ហាញខាងក្រោម។

### ១ សេចក្តីផ្តើមនៃពន្ធប្រព័ន្ធពន្ធកម្ពុជា

**មាតិកាសំខាន់ៗៈ**

1. សេចក្តីផ្តើមទូទៅ និងលក្ខណ:សំខាន់នៃពន្ធដារ
2. គោលនយោបាយសារពើរពន្ធ
3. រដ្ឋបាលសារពើពន្ធ
4. កំណែទម្រង់គោលនយោបាយ និងរដ្ឋបាលសារពើពន្ធ
5. សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ
6. បទល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ

7. ពន្ធបន្ថែមនិងការប្រាក់

**២ កាតព្វកិច្ចសារពើពន្ធសម្រាប់អង្គការសង្គមស៊ីវិល**

**មាតិកាសំខាន់ៗ៖**

**១. ការចុះបញ្ជីពន្ធដារ**

**២. ការប្រកាសបង់ពន្ធ**

**៣. ពន្ធកាត់ទុកទូទៅ**

**៤. ពន្ធលើប្រាក់បៀវត្ស**

**៥. ពន្ធលើប្រាក់ចំណូល**

លោក មាស យាងបានលើកឡើងផងដែរថាប្រជាពលរដ្ឋទាំងអស់ត្រូវមានកាតព្វកិច្ចបង់ពន្ធ ហើយបើអង្គការមានការផ្លាស់ប្តូរការិយាល័យឬ នាយកប្រតិបត្តិ ត្រូវជូនដំណឹងទៅនាយកដ្ឋានពន្ធដារ ។ ជាពិសេសប្រសិនបើអង្គការចង់ឲ្យមានការលើកលែងពន្ធលើប្រាក់ចំណូលត្រូវដាក់ពាក្យប្រកាសពន្ធរួចស្នើសុំការអនុគ្រោះពន្ធឬលើកលែងពន្ធពីក្រសួង។ ជាចុងក្រោយលោកបានលើកទឹកចិត្តដល់អង្គសិក្ខាកាមឲ្យអានឯកសារនិងច្បាប់ពន្ធដារបន្ថែមទៀតដើម្បីឲ្យកាន់តែយល់ច្បាស់។

**ឯកសារទាំងនេះអាចរកបាននៅក្នុងគេហទំព័ររបស់នាយកដ្ឋានពន្ធដារ** [www.tax.gov.kh](http://www.tax.gov.kh)

## ករណីសិក្សា នៃអង្គការ រស់ និង រៀន កម្ពុជា (Live and Learn Cambodia)
## ស្តីពី ការប្រតិបត្តិល្អ និងការផ្លាស់ប្តូរជាវិជ្ជមានក្នុងការគ្រប់គ្រងលទ្ធកម្មក្រោយពេលចូលរួមវេទិកាសិក្សារៀនសូត្រការគ្រប់គ្រងហិរញ្ញវត្ថុ



**អ្នកស្រី កុល សុភាពប្រធានគ្រប់គ្រងហិរញ្ញវត្ថុនិងរដ្ឋបាលនៃអង្គការ រស់ និង រៀន កម្ពុជា** បានចែករំលែកនូវបទពិសោធន៍ល្អៗរបស់ អ្នកស្រីបន្ទាប់ពីបានចូលរួមនៅក្នុងវគ្គវេទិកាសិក្សារៀនស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុដែលរៀបចំដោយអង្គការ គសក។

អ្នកស្រីបានលើកឡើងថាវេទិកាសិក្សារៀនសូត្រនេះមានសារសំខាន់ណាស់ វេទិកានេះបានចែករំលែកនូវចំណេះដឹងនិងបទពិសោធន៍ថ្មីៗនិងការអនុវត្តជាក់ស្តែងជាច្រើនពីសិក្ខាកាម លោកគ្រូ និងអ្នកគ្រូ ដែលយើងមិនអាចរៀនបានពីសាលារៀនទេ។ ជាក់ស្តែង អ្នកស្រីបានទទួលចំណេះដឹងជាច្រើនពីវេទិកាសិក្សារៀនសូត្រនេះហើយបានយកទៅអនុវត្តន៍ផ្ទាល់នៅក្នុងការងារ អ្នកស្រីបន្ថែមថាគាត់ជូនជាអង្គការដល់ពេលវេលាធ្វើការឆ្លុះបញ្ចាំងគោលនយោបាយផង និងដោយយោងទៅលើតួនាទី និងការទទួលខុសផងដែរនោះ អ្នកស្រីត្រូវបាននាយកប្រតិបត្តិនិងបុគ្គលិកថ្នាក់គ្រប់គ្រងផ្តល់ឱកាសឲ្យអ្នកស្រីពិនិត្យមើលឡើងវិញនូវគោលនយោបាយលទ្ធកម្មរបស់អង្គការ។ អ្នកស្រីបានបន្ថែមថា គោលនយោបាយលទ្ធកម្មនេះពីមុនមានការចែងមិនសូវច្បាស់លាស់ពីនិតិវិធីទេ វាដូចជានៅមានភាពទូលំទូលាយពេក ប៉ុន្តែក្រោយពីបានចូលរៀនពីវេទិកាស្តីពី **ការគ្រប់គ្រងលទ្ធកម្ម** អ្នកស្រីយល់ច្បាស់ហើយបានយកទៅកែសម្រួលគោលនយោបាយលទ្ធកម្ម ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធដូចជាបុគ្គលិក នាយកប្រតិបត្តិ និងក្រុមប្រឹក្សាភិបាល បច្ចុប្បន្នគោលនយោបាយលទ្ធកម្មនេះបានចែងយ៉ាងច្បាស់ពីនិតិវិធី ហើយអនុមតិដោយក្រុមប្រឹក្សាភិបា

លៗ ជាងនេះទៅទៀតបុគ្គលិកកាន់តែយល់ច្បាស់និងប្រតិបត្តិតាមដោយយកចិត្តទុកដាក់ជាងពីមុន ដូចជាពល់នៃការទិញទំនិញអ្វីមួយពួកគេដឹងថា ទំនិញនោះមានតម្លៃប៉ុន្មាន អ្នកណាខ្លះចូលរួមនៅក្នុងដំណើរការនិមួយៗជាដើម។ ជាចុងក្រោយអ្នកស្រីលើកទឹកចិត្តដល់អង្គសិក្ខាកាមថា យោងតាមបទពិសោធន៍របស់អ្នកស្រី អង្គការដទៃទៀតគួរតែលើកទឹកចិត្តនិងផ្តល់ឱកាសឲ្យសហការីរបស់ខ្លួនបានចូលរួមវេទិកាសិក្សារៀនសូត្រនេះ វាមានសារសំខាន់ណាស់ ពីព្រោះវាជាវេទិកាដែលចែករំលែកពីបទពិសោធន៍ និងជីវិតការងារប្រចាំថ្ងៃពិតៗ។

*សូមមើលករណីសិក្សាលម្អិតបន្ថែមតាមរយៈវីដេអូខ្លីនិងឯកសាររបស់អ្នកស្រី កុល សុភាព នៅក្នុងវេបសាយរបស់អង្គការគេសក និងនៅឧបសម្ព័ន្ធ។*

## <u>វគ្គទី២</u> បទបង្ហាញអំពី ច្បាប់ស្តីពី "គណនេយ្យ និងសវនកម្ម" ដោយ លោក សេង តុលា អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ



ដើម្បីឲ្យសិក្ខាកាមកាន់តែយល់ច្បាស់អំពីច្បាប់ស្តីពី **គណនេយ្យនិងសវនកម្ម លោក សេង តុលា ជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ** លោកបានធ្វើបទបង្ហាញដោយផ្តោតលើមាតិកាសំខាន់ៗដូចជា៖

1. ការវិវឌ្ឍនៃវិស័យគណនេយ្យនៅកម្ពុជា
2. ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
3. ប្រកាសស្តីពីការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ
4. ទស្សនវិស័យ

### 1. ការវិវឌ្ឍវិស័យគណនេយ្យនៅកម្ពុជា




### 2. ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ([www.naccambodia.gov.kh](www.naccambodia.gov.kh))

ក) មាតិកានៃច្បាប់ (១៣ ជំពូក និង ៣៩ មាត្រា)




## ខ) គោលបំណង គោលដៅ និងវិសាលភាព

- ➢ វិសាលភាព៖ អនុវត្តចំពោះគណនេយ្យករ ក្រុមហ៊ុនគណនេយ្យ
- ➢ ពាក្យគន្លឹះ៖ យើងអាចរកមើលបាននៅក្នុងនិយមន័យ




## គ) ក្របខណ្ឌស្ថាប័ន

❖ តួនាទីក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) (ម ៧)៖

1. រៀបចំធ្វើបច្ចុប្បន្នកម្ម និងអនុម័តសេចក្តីព្រាង៖ ស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម និងវិធាននិងនីតិវិធីអនុវត្តន៍ស្តង់ដាគណនេយ្យនិងសវនកម្ម
2. សម្រេចផ្តល់ ព្យួរ និងដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា
3. រៀបចំ អនុម័ត និងអនុវត្តវិធាននិងនីតិវិធីសម្រាប់ការតាមដាននិងត្រួតពិនិត្យការអនុវត្តច្បាប់និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងគណនេយ្យនិងសវនកម្ម
4. ពិនិត្យនិងដោះស្រាយបណ្តឹងឬវិវាទពាក់ព័ន្ធនឹងគណនេយ្យនិងសវនកម្ម

5. សម្រេចចាត់វិធានការវិន័យឬទណ្ឌកម្មរដ្ឋបាលចំពោះអំពើបំពានបទប្បញ្ញត្តិពាក់ព័ន្ធគណនេយ្យនិងសវនកម្ម
6. តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅចំពោះមុខស្ថាប័នតុលាការ ចំពោះរឿងក្តីពាក់ព័ន្ធគណនេយ្យនិងសវនកម្ម
7. ធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិនិងអន្តរជាតិក្នុងការងារពាក់ព័ន្ធនឹងវិស័យគណនេយ្យនិងសវនកម្ម
8. គ្រប់គ្រងនិងអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម
9. ពិនិត្យ តាមដាន និងវាយតម្លៃលើផែនការ ការអនុវត្តផែនការ និងសកម្មភាពរបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
10. ធ្វើជាតំណាងព្រះរាជាណាចក្រកម្ពុជានៅក្នុងអង្គការជាតិនិងអន្តរជាតិក្នុងវិស័យគណនេយ្យនិងសវនកម្ម។




**លក្ខណ្ឌសម្រាប់សវនករ (ម១៥)**

សវនករមិនអាចផ្តល់សេវាសវនកម្មជូនសហគ្រាសឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលខ្លួនធ្លាប់ផ្តល់សេវាគណនេយ្យឡើយ លើកលែងតែការផ្តល់សេវាគណនេយ្យនោះបានបញ្ចប់ទៅក្នុងរយៈពេលយ៉ាងតិច៣ឆ្នាំ។

សវនករមិនត្រូវបន្តផ្តល់សេវាកម្មជូនសហគ្រាសឬអង្គភាពមិនស្វែងរកប្រាក់ចំណេញណាមួយលើសពីប្រាំឆ្នាំបន្តបន្ទាប់គ្នាឡើយ។

សវនករមិនត្រូវផ្តល់សេវាសវនកម្មជូនសហគ្រាសដែលខ្លួនទទួលផលប្រយោជន៍ឬមានសិទ្ធិគ្រប់គ្រង ទោះដោយផ្ទាល់ក្តីឬដោយប្រយោលក្តី តាមរយៈសហព័ទ្ធ ញាតិលោហិតឬញាតិពន្ធ រហូតដល់ថ្នាក់ទី៣។




ស្តង់ដា
FRS
ស្តង់ដាគណនេយ្យ (ម១១)
ISA
ស្តង់ដាសវនកម្ម (ម១២)
CODE of ETHICS
ក្រមសីលធម៌វិជ្ជាជីវៈ (គណនេយ្យករ និងសវនករ) (ម១៣,១៤)
កំណត់ដោយប្រកាស


គណនេយ្យករនិងសវនករ (ម២៧,២៨)
KICPAA
បុគ្គលគ្រប់រូបទោះជារូបវន្តបុគ្គលក្តី នីតិបុគ្គលក្តី អាចជាគណនេយ្យករនិង/ឬសវនករបាន លុះត្រាតែបានចុះឈ្មោះជាសមាជិករបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម។
ប្រភេទគណនេយ្យករនិងសវនករដែលជាសមាជិករបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យនិងសវនកម្មត្រូវកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម។
ការប្រកបវិជ្ជាជីវៈគណនេយ្យនិង/ឬសវនកម្មមានវិសមិតភាពជាមួយនឹងមុខងារសាធារណៈនិងមុខងារនយោបាយក្នុងអង្គការនីតិប្បញ្ញត្តិ អង្គការនីតិប្រតិបត្តិ និងមុខងារក្នុងអង្គការតុលាការ។


លក្ខខណ្ឌ និងកាតព្វកិច្ចកំណត់ដោយច្បាប់
របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្ម (ម១៦,២៤)
• របាយការណ៍ហិរញ្ញវត្ថុរួមមានរបាយការណ៍នានាដែលត្រូវកំណត់ក្នុងស្តង់ដាគណនេយ្យ
• របាយការណ៍សវនកម្ម រួមមានរបាយការណ៍នានាដែលត្រូវកំណត់ក្នុងស្តង់ដាសវនកម្ម
ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ម១៧)
• មានកាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យបានរួចរាល់ ក្នុងរយៈពេល៣(បី)ខែយ៉ាងយូរបំផុតគិតពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យនីមួយៗ
• ក្នុងករណីមិនអាចរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមកាលកំណត់ក្នុងកថាខណ្ឌខាងលើ សហគ្រាសឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវស្នើសុំពន្យារពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ជាលាយលក្ខណ៍អក្សរទៅក.ជ.គ.ឬទៅនិយ័តករពាក់ព័ន្ធ
ការដាក់របាយការណ៍ហិរញ្ញវត្ថុឯសវនកម្ម (ម១៨)
• អាចតម្រូវឱ្យធ្វើសវនកម្ម
• លក្ខខណ្ឌដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមសំណើរបស់ ក.ជ.គ.
មូលដ្ឋានពន្ធ (ម១៩)
• របាយការណ៍ហិរញ្ញវត្ថុត្រូវធ្វើជាមូលដ្ឋានសម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ
20/10/2017
NAC@2017
14

## លក្ខខណ្ឌ និងកាតព្វកិច្ចកំណត់ដោយច្បាប់(ត)

| | |
|---|---|
| កាន់បញ្ជីគណនេយ្យ (ម២០) | • សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញមានកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ<br>• ស្ថាប័នសាធារណៈមានកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ<br>• ប្រតិបត្តិការគណនេយ្យនីមួយៗត្រូវសំអាងលើសក្ខីបត្រគណនេយ្យដែលមានសុពលភាព |
| ការិយបរិច្ឆេទគណនេយ្យ (ម២១) | • កំណត់រយៈពេលចំនួន១២ខែ (ថ្ងៃទី១ មករា-៣១ ធ្នូនៃឆ្នាំដដែល)<br>• (ទើបបង្កើតថ្មី) ការិយបរិច្ឆេទទី១ គិតចាប់ពីថ្ងៃបង្កើតជាផ្លូវការដល់ថ្ងៃទី៣១ខែធ្នូនៃឆ្នាំដដែល<br>• ការិយបរិច្ឆេទគណនេយ្យអាចត្រូវកំណត់ផ្សេងពីនេះ សម្រាប់សកម្មភាពដែលមានលក្ខណៈពិសេស |
| ភាសានិងរូបិយហិរញ្ញវត្ថុ (ម២២,២៥) | • បញ្ជីគណនេយ្យនិងរបាយការណ៍ហិរញ្ញវត្ថុត្រូវធ្វើជាភាសាខ្មែរនិងជាប្រាក់រៀល<br>• អនុញ្ញាតឱ្យធ្វើជាភាសាអង់គ្លេសនិងជារូបិយបណ្ណបរទេស (កំណត់ដោយប្រកាស)<br>• របាយការណ៍សវនកម្ម ត្រូវរៀបចំឡើងជាភាសាខ្មែរ (អាចអមដោយភាសាអង់គ្លេស) |
| ការរក្សាទុកឯកសារ (ម២៣,២៦) | • ឯកសារគណនេយ្យ និងភស្តុតាងសវនកម្ម ត្រូវរក្សាទុកឱ្យបានគង់វង្ស ១០ ឆ្នាំយ៉ាងតិច ចាប់ពីថ្ងៃដែលឯកសារត្រូវបានបង្កើតឡើង |

NAC@2017 15

## ទោសប្បញ្ញត្តិ

| | |
|---|---|
| **ប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌វិជ្ជាជីវៈ (ម៣១)** | • ការស្តីបន្ទោសដោយផ្ទាល់មាត់<br>• ការស្តីបន្ទោសដោយមានចំណារក្នុងសំណុំផ្ទាល់ខ្លួន<br>• ការហាមមិនឲ្យប្រកបវិជ្ជាជីវៈជាបណ្តោះអាសន្ន<br>• ការហាមមិនឲ្យប្រកបលិខិតវិជ្ជាជីវៈជាអចិន្ត្រៃយ៍ |
| **បទល្មើស (ម៣២)** | • ពិន័យអន្តរការណ៍ដែលត្រូវកំណត់ដោយអនុក្រឹត្យ |
| **គ្មានអាជ្ញាបណ្ណ (ម៣៣)** | • ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី២០០០០០០(ពីរលាន)រៀលទៅ៨០០០០០០(ប្រាំបីលាន)រៀល |
| **មិនប្តឹងបរិហារពីបទល្មើស (ម៣៤)** | • ត្រូវផ្តន្ទាទោសតាមបញ្ញត្តិនៃមាត្រា៥២៨(បទមិនប្តឹងបរិហារបទឧក្រិដ្ឋឬបទមជ្ឈិមដោយអ្នករាជការសាធារណៈ: ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។ |
| **ក្លែងរបាយការណ៍សវនកម្ម (ម៣៥)** | • ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៨០០០០០០(ប្រាំបីលាន)រៀលទៅ២០០០០០០០(ម្ភៃលាន)រៀល |

## ទោសប្បញ្ញត្តិ (ត)

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៣៤ និងមាត្រា៣៥ នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៩២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ

**នីតិបុគ្គលត្រូវពិន័យជាប្រាក់ពី១០០០០០០០(ដប់លាន)រៀលទៅ៥០០០០០០០(ហាសិបលាន)រៀល**

+

1) ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។
2) ការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។
3) ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។
4) ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយសេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ។
5) ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

20/10/2017 NAC@2017 17

❖ *សម្គាល់៖ សូមលើកទឹកចិត្តដល់អង្គសិក្ខាកាម បើជួលសវនកម្ម សូមជួលក្រុមហ៊ុនដែលមានការទទួលស្គាល់លក្ខណៈផ្លូវច្បាប់មកធ្វើសវនកម្មអង្គការ(ហាមជួលបុគ្គល)។*

# ប្រកាសស្តីពីការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

## គោលបំណង

- ប្រកាសនេះ មានគោលបំណងដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញទាំងអស់ដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន(**ប្រការ១**)។
- មូលដ្ឋានក្នុងការរៀបចំស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ (ត្រូវរៀបចំឡើងដោយផ្អែកលើមូលដ្ឋាន***គណនេយ្យសាច់ប្រាក់*** (**ប្រការ៣**)

## ❖ កាតព្វកិច្ចរបស់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

- ☞ កាតព្វកិច្ចកាន់បញ្ជីគណនេយ្យ
- ☞ រៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវដូចមានចែងនៅក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។
- ☞ កាតព្វកិច្ចបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមកក្រុមប្រឹក្សាជាតិគណនេយ្យ។
- ☞ កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ តាម លក្ខខណ្ឌ និងនីតិវិធី ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



## ❖ បដិប្បញ្ញត្តិ

អង្គភាពមិនស្វែងរកប្រាក់ចំណេញដែលមិនអាចរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញដូចកំណត់ក្នុងប្រកាសនេះ ត្រូវស្នើសុំការអនុញ្ញាតពី ក.ជ.គ ជាមុន ឬត្រូវជូនដំណឹងមក ក.ជ.គ. គណនេយ្យ ក្នុងករណីអង្គភាពមិនស្វែងរកប្រាក់ចំណេញនោះអនុវត្តស្តង់ដាគណនេយ្យកម្ពុជា ជាធរមាន។

- **សម្គាល់៖** ក្នុងករណីប្រើស្តង់ដាណាមួយនៃស្តង់ដាទាំង៣នេះ (ស្តង់ដាគណនេយ្យ (ម១១), ស្តង់ដាសវនកម្ម (ម១២), ក្រមសីលធម៌វិជ្ជាជីវៈ (គណនេយ្យករ និងសវនករ) (ម១៣,១៤) ដោយគ្រាន់ជូនដំណឹង ទៅក.ជ.គ។
- រាល់ការរៀបចំតារាងគណនេយ្យ និងប្រព័ន្ធគណនេយ្យត្រូវតម្រូវត្រូវទៅតាមទម្រង់ដែលក្រសួងបានផ្តល់ឲ្យ។

## ❖ ការតម្រូវផ្សេងទៀត

អង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវមានលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុ ដែលបែបបទ និងនីតិវិធីនៃការផ្តល់លេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុត្រូវកំណត់ដោយក្រុមប្រឹក្សាជាតិគណនេយ្យ។

❖ **សម្គាល់៖** ត្រូវស្នើសុំលេខកូដនិងទម្រង់របាយការណ៍ហិរញ្ញវត្ថុ (អាចស្នើសុំតាមប្រព័ន្ធអេឡិចត្រូនិក online) ពីក្រុមប្រឹក្សាជាតិគណនេយ្យ។

## ទស្សនវិស័យ

- បង្កើតស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនមធ្យម
- បង្កើតស្តង់គណនេយ្យសម្រាប់វិស័យសាធារណៈ
- បង្កើតស្តង់ដាគណនេយ្យសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ
- បង្កើតកម្មវិធីសិក្សាគណនេយ្យជំនាញជាតិ
- ត្រួតពិនិត្យ និងតាមដានការអនុវត្តច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធ ជាធរមាន
- ពង្រឹងការគ្រប់គ្រងវិជ្ជាជីវគណនេយ្យ និងសវនកម្ម ឱ្យកាន់តែមានប្រសិទ្ធភាព
- ពង្រឹងគុណភាពសវនកម្ម

| សំនួរ | ចម្លើយ |
|---|---|
| ១. ប្រការ៥ នៃប្រកាស ៣៣៥ ពាក់ព័ន្ធទៅនឹងការអនុវត្តស្តង់ដាគណនេយ្យ (FRS) ? | CIFRS ត្រូវជូនដំណឹង |
| ២. បន្ទាប់ពីការជូនដំណឹងទៅក.ជ.គ តើត្រូវរង់ចាំការឆ្លើយតបទេ? ហើយបើសិនជាអង្គការប្រើ cash modify basis ត្រូវជូនដំណឹងដែរឬទេ? | ការជូនដំណឹងមិនចាំបាច់រង់ចាំទេ<br>បើអង្គការបានអនុវត្តដល់ប្រព័ន្ធ cash modify basis មិនចាំបាច់ជូនដំណឹងទៅក.ជ.គ ទេ។ |
| ៣. របាយការណ៍តាមឆ្នាំសារពើពន្ធ ត្រូវតែតម្រូវតាមឆ្នាំប្រតិទិន? តើអត្រាប្តូរប្រាក់គិតដូចម្តេច? | ក្នុងករណីមានឆ្នាំសារពើពន្ធខុសគ្នាត្រូវស្នើសុំទៅក.ជ.គ អំពីការប្រើប្រាស់ឆ្នាំសារពើពន្ធរបស់អង្គការសាម៉ី។<br>អត្រាប្តូរប្រាក់៖ គិតជារូបបិយប័ណ្ណប្រតិបត្តិ និងរូបបិយប័ណ្ណរៀល។ កត់ត្រាអាចនៅពេលដែលមានការប្តូរ ប្រាក់ យកតាម ធនាគារជាតិនៅពេលបិទបញ្ជីប្រចាំឆ្នាំ។ |
| ៤. ការដាក់របាយការណ៍ប្រចាំឆ្នាំទៅ ក.ជ.គ តាមប្រតិទិនប្រចាំឆ្នាំ តែបើសិនជាអង្គការចប់មុនគិតដូចម្តេច? | ក្នុងករណីឆ្នាំសារពើពន្ធចប់មុនត្រូវស្នើសុំ ទៅក.ជ.គ (យកអត្រាប្តូរប្រាក់នៅពេលបិទបញ្ជី) |
| ៥. ក្រសួងសេដ្ឋកិច្ចនេះសំដៅទៅក.ជ.គឬ? | បច្ចុប្បន្នផ្ញើទៅក្រសួង ហើយក.ជ.គ គឺជាសេនាធិការរបស់ក្រសួង។<br>ការផ្ញើរបាយការណ៍ត្រូវបិទបញ្ជីគឺមិនចាំបាច់រង់ចាំសវនកម្មទេ បើសិនស្ថាប័ននោះមិនជាប់សវនកម្ម (នឹងមានសេចក្តីប្រកាសស្តីពីសវនកម្ម) ។ ហើយសវនកម្មបច្ចុប្បន្នជាការស្ម័គ្រចិត្តឬតម្រូវការរបស់ម្ចាស់មូលនិធិ |
| ៦. ពេលចុះអនុសារណៈតែងតែមានការស្នើសុំរបាយការណ៍ តើមានរបាយការណ៍ផ្សេង | មានតែរបាយការណ៍ស្តង់ដាគណនេយ្យនេះទេ |

| | |
|---|---|
| ពីរបាយការណ៍ស្តង់ដាឬយ៉ាងណា? | |
| ៧. តើមានអ្វីដែលបញ្ជាក់ថាយើងកំពុងអនុវត្តតាមស្តង់ដាគណនេយ្យ? | របាយការណ៍អាចភ្ជាប់ជាមួយនូវរបាយការណ៍សវនកម្ម (IFRS or CFRS) |
| ៨. ការដាក់របាយការណ៍មិនទាន់ ត្រូវស្នើសុំពន្យាមានរយៈពេលដែរឬទេ? មានទម្រង់ទេ? | ពន្យានៃការបិទបញ្ជីរបាយការណ៍ហិរញ្ញវត្ថុ មិនមែនការពន្យាការដាក់របាយការណ៍ទេ។ រយៈពេលនៃការសុំពន្យារយៈពេលនៃការបិទបញ្ជីមិនទាន់មានកំណត់ទេ។ គំរូស្នើសុំមិនទាន់មានទេ តែអាចប្រើលិខិតរបស់អង្គភាពខ្លួនឯងបាន។ |
| ៩. តើយើងអាចផ្ញើរបាយការណ៍ហិរញ្ញវត្ថុមុនបញ្ចប់របាយការណ៍សវនកម្មបានដែរឬទេ? | យើងអាចផ្ញើរបាយការណ៍ហិរញ្ញវត្ថុមុនរបាយការណ៍សវនកម្មបានពីព្រោះច្បាប់មិនទាន់តម្រូវឲ្យមានសវនកម្មនៅឡើយ ឬនៅពេលបញ្ចប់សវនកម្មផ្ញើក៏បានដែរ។ |
| ១០. តើការបិទបញ្ជីហិរញ្ញវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុដូចគ្នាឬទេ? | ការបិទបញ្ជីហិរញ្ញវត្ថុ គឺដើម្បីការធ្វើរបាយការណ៍ហិរញ្ញវត្ថុ |
| ១១. តើថវិកាជំនួយដោយផ្ទាល់ទៅអង្គការដៃគូក្រោមឈ្មោះរបស់អង្គការយើង គួរដាក់ក្នុងរបាយការណ៍ដែរឬទេ? | ការកត់ត្រាចំណូល (របស់អង្គភាពតែមួយ) មិនមែនជាចំណូលទេ។ |
| ១២. កម្ចីត្រូវកត់យ៉ាងដូចម្តេច? | ការខ្ចីលុយ (ចំណូលជាកម្ចី កត់ត្រាជាចំណូលមូលធន) |
| ១៣. ប្រសិនបើយើងបានអនុវត្តន៍ ISRF ត្រូវជូនដំណឹងទៅក.ជ.គដែរឬទេ? | ប្រសិនបើយើងបានអនុវត្តន៍ ISRF ត្រូវជូនដំណឹងទៅក.ជ.គ ដោយបញ្ជាក់ថារបាយការណ៍ត្រូវបានធ្វើតាមស្តង់ដាISRF ។ |
| ១៤. បើអង្គការទើបមានសកម្មភាពរយៈពេលខ្លីក្នុងឆ្នាំ២០១៨ តើត្រូវធ្វើរបាយការដែរឬទេ? | អង្គភាពទាំងអស់ត្រូវតែធ្វើរបាយការណ៍ទោះជាមានសកម្មភាពតែមួយសប្តាហ៍ក៏ដោយ។ |

## វគ្គទី៣: បទបង្ហាញស្តីពី "ក្របខ័ណ្ឌនៃការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ"

### ដោយ លោក សេង តុលា អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ



លោក សេង តុលា បានបន្តការធ្វើបទបង្ហាញនិងពន្យល់ដល់អង្គសិក្ខាកាមស្តីពី"ក្របខ័ណ្ឌនៃការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ"ដោយមានមាតិកាសំខាន់ៗដូចជា៖

- ❖ គោលបំណង
- ❖ វិសាលភាព
- ❖ ស្តង់ដា
- ❖ កាលបរិច្ឆេទចូលជាធរមាន
- ❖ ភាគ ក៖ លក្ខខណ្ឌចាំបាច់ជាក់លាក់
- ❖ ភាគ ខ៖ ការរៀបចំអន្តរកាល

- **គោលបំណង**
  - ▶ គុណភាពនៃព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុ
  - ▶ សង្គតិភាពព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុ
  - ▶ ការប្រៀបធៀបពីអង្គភាពមួយទៅអង្គភាពមួយ
  - ▶ ការប្រៀបធៀបពីការិយបរិច្ឆេទមួយទៅការយបរិច្ឆេទមួយទៀត

- **វិសាលភាព**
  - ▶ ស្តង់ដានេះអនុវត្តចំពោះតែអង្គភាពមិនស្វែងរកប្រាក់ចំណេញទាំងអស់ដែលត្រូវបានបង្កើតឡើងដោយអនុលោមតាម៖
    - ច្បាប់ស្តីពីសមាគម
    - អង្គការមិនមែនរដ្ឋាភិបាល
    - បទប្បញ្ញត្តិពាក់ព័ន្ធជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- **ស្តង់ដារ៖** អនុវត្តតាមមូលដ្ឋានគណនេយ្យសាច់ប្រាក់ (cash-based accounting)
- **កាលបរិច្ឆេទចូលជាធរមាន**
    - អង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវអនុវត្តន៍ស្តង់ដានេះចាប់ពីឬក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨តទៅ។
    - ឆ្នាំប្រតិទិន ថ្ងៃទី ០១ មករា ដល់ ថ្ងៃទី៣១ ធ្នូ នៃឆ្នាំនីមួយៗ។ នៅពេលរាយការណ៍អ្វីដែលប្រតិបត្តិការនៅបំណាច់ឆ្នាំ។មូលដ្ឋានគណនេយ្យបង្ករវាមានប្រយោជន៍ដល់ការធ្វើរបាយការណ៍របស់យើង។

## ភាគ គ៖ លក្ខខណ្ឌចាំបាច់ជាក់លាក់

### ▶ ផ្នែកទី១៖ សេចក្តីណែនាំ

- កំណត់ពីលក្ខខណ្ឌចាំសម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុវាក្យសព្ទត្រូវបានកំណត់នៅក្នុងសទ្ទានុក្រមក្នុងផ្នែកទី៧។

### ▶ ផ្នែកទី២៖គោលបំណងនៃការរៀបចំរបាយការណ៍និងទិដ្ឋភាពទូទៅនៃលក្ខខណ្ឌចាំបាច់សម្រាប់របាយការណ៍គោលបំណងនៃការរាយការណ៍



1. ទិដ្ឋភាពទូទៅរបស់អង្គភាព
2. គោលដៅរបស់អង្គភាព
3. សកម្មភាពរបស់អង្គភាពនៅក្នុងឆ្នាំ
4. ចំណូលនិងចំណាយនៅក្នុងឆ្នាំ
5. ប្រភពសាច់ប្រាក់ដែលទទួលបាន
6. ការិយបរិច្ឆេទនៃរបាយការណ៍និងការប្រៀបធៀបព័ត៌មាននៃរបាយការណ៍ជាមួយការិយបរិច្ឆេទរាយការណ៍មុន
7. គោលនយោបាយគណនេយ្យដែលអង្គភាពបានអនុវត្តន៍
8. សមត្ថភាពរបស់អង្គភាពបន្តសម្រេចបាននូវគោលបំណងនិងប្រតិបត្តិការរបស់ខ្លួននៅពេលអនាគត។

### ▶ សមាសធាតុចាំបាច់នៃរបាយការណ៍ហិរញ្ញវត្ថុ

1. ព័ត៌មានរបស់អង្គភាពដែលពន្យល់អំពីអង្គភាព
2. របាយការណ៍ចំណូលនិងចំណាយដែលបង្ហាញអំពីសាច់ប្រាក់ដែលបានទទួលនិងបានទូទាត់ដោយអង្គភាព
3. កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

### ▶ ព័ត៌មានទូទៅ

របាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពត្រូវរួមបញ្ចូលរាល់សកម្មភាពទាំងអស់របស់អង្គភាពដូចជា៖

1. ព័ត៌មានរបស់សាខាទាំងអស់ឬអង្គភាពប្រតិបត្តិចំណុះ
2. ការកំណត់អត្តសញ្ញាណអំពីសាខាឬអង្គភាពប្រតិបត្តិចំណុះនានាដែលស្ថិតនៅក្រោមអង្គភាពមានទំនាក់ទំនងផ្ទាល់ជាមួយនឹងទម្រង់ច្បាប់(Legal Form)ដែលអង្គភាពមាន។

### ▶ សង្គតិភាពនៃការដាក់បង្ហាញ

- ☞ ចំនួនទឹកប្រាក់ទាំងអស់ត្រូវកំណត់ជាប្រាក់រៀលផ្អែកលើអត្រាប្តូរប្រាក់ផ្លូវការដែលបោះផ្សាយដោយធនាគារជាតិនៃកម្ពុជា។
- ☞ អង្គភាពមិនត្រូវផ្លាស់ប្តូររបៀបបង្ហាញព័ត៌មាន ឬផ្លាស់ប្តូរខ្ទង់នៃការលាតត្រដាងពីការិយបរិច្ឆេទមួយទៅការិយបរិច្ឆេទមួយទៀត លើកលែងតែ៖
  - ✓ មានការផ្លាស់ប្តូរជាសារវន្តណាមួយនៃកិច្ចប្រតិបត្តិការរបស់អង្គភាព ឬ
  - ✓ ស្តង់ដានេះតម្រូវឲ្យមានការផ្លាស់ប្តូរការដាក់បង្ហាញឬខ្ទង់នៃការលាតត្រដាង។

- **ការមិនកាត់កងចំនួនទឹកប្រាក់**
  - ☞ សាច់ប្រាក់ដែលបានទទួលនិងសាច់ប្រាក់ដែលបានទូទាត់(ទោះបីក្នុងគោលបំណងប្រហាក់ប្រហែលក៏ដោយ)មិនត្រូវកាត់កងគ្នាឡើយ។
- **ការកែតម្រូវកំហុសឆ្គង**
  - ☞ កំហុសជាសារវន្តត្រូវបានកែឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន
  - ☞ កំហុសឆ្គងដែលកើតឡើងក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ត្រូវកែតម្រូវមុនពេលបិទបញ្ចប់របាយការណ៍ហិរញ្ញវត្ថុ
  - ☞ កំហុសឆ្គងជាសារវន្តដែលទាក់ទងនឹងការិយបរិច្ឆេទមុនត្រូវបានកែតម្រូវ និងលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំនេះមុនពេលបិទបញ្ចប់នៃរបាយការណ៍។

- **ផ្នែកទី៣៖ ព័ត៌ មានរបស់អង្គភាព**
  - **គោលបំណងនិងតម្លៃចំពោះអ្នកប្រើប្រាស់:**

1. សង្ខេបឲ្យអ្នកប្រើប្រាស់បានដឹងអំពីអ្វីដែលអង្គភាពបានធ្វើ និងរបៀបដែលអង្គភាពបានរៀបចំ
2. ជួយអ្នកប្រើប្រាស់ក្នុងការយល់ដឹងអំពីអង្គភាព និងជាពិសេសជួយដល់ពួកគេក្នុងការបកស្រាយលើរបាយការណ៍ហិរញ្ញវត្ថុ

- **ព័ត៌មានចាំបាច់**

1. ឈ្មោះនិងប្រភេទរបស់អង្គភាព
2. លេខចុះបញ្ជីនិងលេខចុះអត្តសញ្ញាណកម្មសារពើពន្ធ អ.ត.ប របស់អង្គភាព(ប្រសិនបើមាន)
3. គោលបំណងរបស់អង្គភាព
4. ការបរិយាយអំពីអង្គការលេខរបស់អង្គភាព(រួមទាំងអភិបាលកិច្ច)
5. ប្រភពចម្បងនៃសាច់ប្រាក់និងធនធានរបស់អង្គភាព
6. វិធីសាស្ត្រចម្បងដែលអង្គភាពប្រើប្រាស់ក្នុងការប្រមូលនិធិ
7. ការពឹងផ្អែករបស់អង្គភាពទៅលើអ្នកស្ម័គ្រចិត្តនិងទំនិញឬសេវាបានពីការបរិច្ចាគ
8. ព័ត៌មានបន្ថែមរបស់អង្គភាពដែលត្រូវបានចាត់ទុកថាមានសារៈសំខាន់ដល់ការយល់ដឹងជាទូទៅរបស់អ្នកប្រើប្រាស់។

- **ផ្នែកទី៤៖ របាយការណ៍ចំណូល និងចំណាយ**
  - ☞ **ចំណូល (ចាំបាច់)**

**ចំណូលកិច្ចប្រតិបត្តិការ៖**

ក) ការបរិច្ចាគ ការរៃអង្គាសប្រាក់ និងចំណូលប្រហាក់ប្រហែលផ្សេងទៀត

ខ) កម្រៃ ការចូលរួមវិភាគទាន និងចំណូលផ្សេងទៀតពីសមាជិក

គ) ចំណូលពីការលក់ទំនិញ ឬសេវា និង

ឃ) ការប្រាក់ ភាគលាភ និងចំណូលពីការវិនិយោគផ្សេងៗ។



▶ **ចំណូលមូលធន**

(គឺជាចំណូលដែលទទួលបានពីការលក់ទ្រព្យសម្បត្តិឬធនធានរបស់អង្គភាព )

ង) ចំណូលពីការលក់ធនធាននិង

ច) ចំណូលពីកម្ចី



☞ **ចំណូល (ព័ត៌មានជម្រើស)**

✓ ***ចំណូលប្រតិបត្តិការ***

ក) ការបរិច្ចាគពីសាធារណជន

ខ) ចំណូលពីការរៃអង្គាសប្រាក់

គ) អំណោយមិនទាក់ទងផ្ទាល់នឹងការផ្តល់សេវា

ឃ) កម្រៃនិងការចូលរួមវិភាគទានពីសមាជិក

ង) ការបរិច្ចាគ ឬការផ្តល់នានាពីសមាជិក

ច)ចំណូលពីអំណោយឬកិច្ចសន្យាសម្រាប់សេវាជាមួយរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ឆ) ចំណូលពីអំណោយឬកិច្ចសន្យាសម្រាប់សេវាជាមួយភ្នាក់ងារមិនមែនរដ្ឋាភិបាល

☞ **ចំណាយ (ព័ត៌មានចាំបាច់)**

✓ ចំណាយកិច្ចប្រតិបត្តិការ

ក) ចំណាយទាក់ទងនឹងការរៃអង្គាសប្រាក់ជាសាធារណៈ

ខ) ចំណាយទាក់ទងនឹងនិយោជិកនិងអ្នកស្ម័គ្រចិត្ត

គ) ចំណាយទាក់ទងនឹងការផ្តល់ទំនិញ ឬសេវា និង

ឃ) អំណោយ និងបរិច្ចាគដែលបានទូទាត់

☞ **ចំណាយមូលធន** (គឺជាការចំណាយទៅលើសម្ភារការិយាល័យ)

ង) ការទិញធនធាន និង

ច) ការសងកម្ចី

☞ **ចំណាយ (ព័ត៌មានជម្រើស)**

**ចំណាយកិច្ចប្រតិបត្តិការ**

ក) ចំណាយរដ្ឋបាលនិងផ្សេងៗ

ខ) ចំណាយភតិសន្យា និងការជួល

គ) កម្រៃលើសម្ព័ន្ធភាព

ឃ) ចំណាយការប្រាក់ និង

ង) ចំណាយលើកម្មវិធី ឬតាមគម្រោង

ច) ចំណាយលើកិច្ចប្រតិបត្តិការផ្សេងទៀត

☞ **គណនីធនាគារនិងសាច់ប្រាក់ (ព័ត៌មានចាំបាច់)**

ក) គណនីធនាគារ

ខ) ប្រាក់បញ្ញើមានកាលកំណត់ និង

គ) សាច់ប្រាក់ក្នុងដៃ

☞ **ព័ត៌មានដទៃទៀត (ព័ត៌មានជម្រើស)**

របាយការណ៍ចំណូលនិងចំណាយត្រូវរួមបញ្ចូលនូវព័ត៌មានបន្ថែមណាដែលត្រូវចាត់ទុកថាចាំបាច់សម្រាប់អ្នកប្រើប្រាស់ ដើម្បីយល់ដឹងពីលទ្ធផលហិរញ្ញវត្ថុរបស់អង្គភាព

☞ **ព័ត៌មានដទៃទៀត (ព័ត៌មានចាំបាច់)**

អង្គភាពអាចបញ្ចូលនូវគម្រោងថវិកា ឬផែនការរបស់អង្គភាពសម្រាប់ឆ្នាំហិរញ្ញវត្ថុនេះបើសិនជាមាន។

## ▶ ផ្នែកទី៥៖ កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

☞ **គោលបំណង និងតម្លៃចំពោះអ្នកប្រើប្រាស់**

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវព័ត៌មានដូចជា៖

- ✓ ព័ត៌មានបន្ថែមលើព័ត៌មានដែលមានក្នុងផ្នែកផ្សេងៗទៀតនៃរបាយការណ៍ហិរញ្ញវត្ថុ
- ✓ ព័ត៌មានបន្ថែមលើព័ត៌មានដែលបានផ្តល់ក្នុងរបាយការណ៍ចំណូលនិងចំណាយ
- ✓ ព័ត៌មានដែលទាក់ទងនឹងសមិទ្ធកម្មសេវា និងធនធាននិងកាតព្វកិច្ច

☞ **ព័ត៌មានចាំបាច់**

- ✓ មូលដ្ឋាននៃការរៀបចំ
- ✓ អារករលើតម្លៃបន្ថែម(អ ត ប)
- ✓ ការកែតម្រូវលើកំហុសឆ្គង
- ✓ ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ
- ✓ ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

☞ **ព័ត៌មានជាជម្រើស** (មានន័យថាអង្គភាពចង់បង្ហាញក៏បានមិនបង្ហាញក៏បាន)

ក) លទ្ធផល

ខ) ទិន្នផល

គ) បញ្ជីធនធាន

ឃ) បញ្ជីកាតព្វកិច្ច

ង) បញ្ជីព័ត៌មានផ្សេងទៀត

ច) បញ្ជីធនធាន (កត់ត្រានូវបុរេប្រទានដែលមិនទាន់បានទូទាត់នៅក្នុងបញ្ជីធនធាន)

☞ **ព័ត៌មានបន្ថែម**

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុត្រូវរួមបញ្ចូលនូវរាល់ព័ត៌មានបន្ថែមណាដែលអង្គភាពគិតថាចាំបាច់សម្រាប់អ្នកប្រើប្រាស់ដើម្បីយល់អំពីលទ្ធផល និងស្ថានភាពហិរញ្ញវត្ថុជារួមរបស់អង្គភាព។

## ▶ ផ្នែកទី៦៖ ឧទាហរណ៍គំរូ

1. អំណោយមានលក្ខខ័ណ្ឌ
2. ការអនុគ្រោះលើកម្ចី
3. សេវាស្ម័គ្រចិត្ត
4. អច្ច័យទាន
5. ចំណូលសម្រាប់សកម្មភាពពេលខាងមុខ
6. ភាគីពាក់ព័ន្ធ

សម្រាប់ឧទាហរណ៍គំរូ សូមមើលក្នុងឯកសារជូនភ្ជាប់

## ▶ ផ្នែកទី៧៖ សន្ធានុក្រម

- **ភាគ ខ៖ ការរៀបចំអន្តរកាល**

### ▶ គោលបំណង

☞ ផ្នែកនេះនៃស្តង់ដាត្រូវបានរៀបចំឡើងដើម្បីជួយដល់អង្គភាពក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុលើកដំបូងរបស់ខ្លួនឲ្យស្របតាមស្តង់ដានេះ។ ស្តង់ដានេះទទួលស្គាល់ថាអង្គភាពមានមូលដ្ឋានរាយការណ៍ខុសៗគ្នា ហើយបានកំណត់នូវវិធានអន្តរកាលផ្សេងគ្នា ដើម្បីបំពេញសេចក្តីត្រូវការទៅតាមស្ថានភាពខុសៗគ្នារបស់អង្គភាព។

### ▶ ក្រុមអន្តរកាល

☞ **ក្រុមទី១ អង្គភាពថ្មី**

ពុំតម្រូវឲ្យមានតួលេខប្រៀបធៀបសម្រាប់ក្រុមនេះឡើយ។ ការលើកលែងនេះនឹងបដិសេធនូវរាល់លក្ខខណ្ឌចាំបាច់នានាដែលមាននៅក្នុងស្តង់ដានេះសម្រាប់ព័ត៌មានប្រៀបធៀបដែលត្រូវរាយការណ៍។ អង្គភាពថ្មីត្រូវលាតត្រដាងនូវកាលបរិច្ឆេទចាប់ផ្តើមរបស់គេនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ។

### ▶ ក្រុមទី២ អង្គភាពកំពុងដំណើរការ

✓ ក) អនុវត្តន៍ស្តង់ដានេះពីការចាប់ផ្តើមនៃការិយបរិច្ឆេទនេះ។ ក្នុងករណីនេះព័ត៌មានប្រៀបធៀបមិនតម្រូវឲ្យមានការបង្ហាញនោះទេ ហើយការលើកលែងនេះនឹងបដិសេធរាល់លក្ខខណ្ឌចាំបាច់នានានៅក្នុងស្តង់ដានេះសម្រាប់ព័ត៌មានប្រៀបធៀបដែលត្រូវរាយការណ៍។ អង្គភាពអនុវត្តន៍តាមស្តង់ដានេះលើកដំបូងដែលជ្រើសរើសមិនបង្ហាញឡើងវិញនូវព័ត៌មានប្រៀបធៀបត្រូវលាតត្រដាងអំពីហេតុការណ៍នោះ ឬ

✓ ខ) អនុវត្តន៍តាមស្តង់ដានេះពីការចាប់ផ្តើមនៃការិយបរិច្ឆេទមុនដោយធ្វើការបងហាញឡើងវិញនូវរបាយការណ៍ហិរញ្ញវត្ថុឆ្នាំមុន(ប្រសិនបើមាន) ដោយអនុលោមតាមលក្ខខណ្ឌចាំបាច់នានានៃស្តង់ដានេះ។ នេះមានន័យថាតួលេខឆ្នាំនេះនិងតួលេខប្រៀបធៀបឆ្នាំមុននឹងត្រូវបានរាយការណ៍តាមមូលដ្ឋានដូចគ្នា។

#### ▶ មូលដ្ឋានសម្រាប់ការសន្និដ្ឋាន

- ☞ សារតារ
- ☞ គោលបំណង
- ☞ វិធីសាស្រ្ត
- ☞ ព័ត៌មានហិរញ្ញវត្ថុ
- ☞ ព័ត៌មានមិនមែនហិរញ្ញវត្ថុ
- ☞ ភាគីពាក់ព័ន្ធ
- ☞ កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
- ☞ ការផ្លាស់ប្តូរ

## បទបង្ហាញអំពី គំរូរបាយការណ៍សម្រាប់អង្គការមិនស្វែងរកប្រាក់ចំណេញ ដោយលោក យ៉ាង ជីញលីង មន្ត្រី នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ

លោក យ៉ាង ជីញលីង មន្ត្រី នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យលោកបានពន្យល់និងបង្ហាញអំពីរបៀបនៃការបំពេញគំរូរបាយការណ៍ដល់សិក្ខាកាមទៅតាមទម្រង់នីមួយៗ។ ក្នុងទម្រង់របាយការណ៍នេះបើផ្នែកណាមួយមិនមានទិន្នន័យទេ យើងដាក់ថា (N/A) ផ្អែកការធានាទៅលើគុណភាពសេវា ។ ការដាក់របាយការណ៍ទៅ ក.ជ.គ ត្រូវដាក់ជាឯកសាររឹង ដោយភ្ជាប់ជាមួយនូវ លិខិតរៀបរាប់អំពីរបាយការណ៍ដោយបោះត្រារបស់អង្គការ



**សូមមើលទម្រង់គំរូដូចមានភ្ជាប់ជាមួយខាងក្រោមនេះ**

40- Template NGO (New)_updated_M.p

## វគ្គទី៥ លទ្ធផលនៃការវាយតម្លៃបញ្ចប់វគ្គវេទិកាសិក្សារៀនសូត្រ

តារាងខាងក្រោមនេះនឹងបង្ហាញនូវលទ្ធផលនៃវគ្គសិក្សារៀនសូត្រក្នុងរយៈពេលមួយថ្ងៃពេញ

| ប្រធានបទ | មិនពេញចិត្តទាល់តែសោះ (%) | មិនពេញចិត្ត (%) | ធម្មតា (%) | ពេញចិត្ត (%) | ពេញចិត្តខ្លាំងណាស់ (%) |
|---|---|---|---|---|---|
| ទីកន្លែង | | | 6% | 72% | 22% |
| ការផ្តល់ជូនផ្នែកភស្តុភា | 1% | 1% | 18% | 63% | 17% |
| ការយល់ដឹងរបស់សិក្ខាលើមេរៀននិងខ្លឹមសារនៃមាតិកាសំខាន់ៗ | | 1% | 34% | 56% | 10% |
| វិធីសាស្ត្រនៃការពន្យល់របស់វាគ្មិន | | 1% | 46% | 43% | 10% |
| ការចែករំលែកបទពិសោធន៍របស់វាគ្មិន | | 1% | 47% | 42% | 10% |
| រយៈពេល | 1% | 13% | 44% | 33% | 9% |

▶ ***ចំណុចសំខាន់ៗមួយចំនួនដែលសិក្ខាកាមចាប់បានច្បាស់ល្អពីវគ្គវេទិកានេះមានដូចជា៖***

- យល់ច្បាស់អំពីរបៀបនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុវត្តន៍តាមរបៀបIFRS & NFPEs)
- យល់ពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

- ការរៀបចំប្រព័ន្ធហិរញ្ញវត្ថុដោយផ្អែកលើគោលការណ៍របស់ ក.ជ.គ
- យល់បានច្រើនពីធនធានដែលធ្វើរបាយការណ៍ហិរញ្ញវត្ថុដាក់ទៅក្រសួងហិរញ្ញវត្ថុ
- បានដឹងពីការណែនាំ និង ការអនុវត្តតាមប្រព័ន្ធcash basis នឹង គោលការណ៍ណែនាំ CFRS
- ដឹងពីកន្លែងទាញយកឯកសារ
- ដឹងពីការធ្វើឯកសារត្រូវធ្វើជាភាសាខ្មែរ
- បានដឹងរយៈពេលនៃការធ្វើរបាយការណ៍ត្រូវកំណត់ជារៀងរាល់ខែមិនានៃឆ្នាំបន្ទាប់

▶ ***ចំណុចសំខាន់ៗដែលនឹងត្រូវបានយកទៅអនុវត្តន៍ដើម្បីឲ្យជំនាញនិងការអនុវត្តការងារនៅក្នុងអង្គការរបស់គេកាន់តែប្រសើរឡើង៖***

- នឹងយកទៅអនុវត្តន៍តាមទាំងអស់
- ដាក់លិខិតទៅក្រុមប្រឹក្សាដាក់គណនេយ្យទៅលើស្តង់ដារគណនេយ្យរបស់អង្គភាព
- របៀបបំពេញទៅលើទម្រង់របាយការណ៍ហិរញ្ញវត្ថុថ្មីៗ សមស្របតាមស្តង់ដា
- ការដាក់ជូនរបាយការណ៍ហិរញ្ញវត្ថុទៅ ក្រុមប្រឹក្សាគណនេយ្យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងក្រសួងពាក់ព័ន្ធ
- ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ គណនេយ្យ និងទម្រង់ហិរញ្ញវត្ថុ
- បទពិសោធន៍នៃការធ្វើរបាយការណ៍
- បង្ហាញពីវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
- យល់គ្រប់មេរៀនទាំងអស់ ហើយនឹងចែករំលែកបន្ត
- កែតម្រូវកំហុសឆ្គងដែលមាននៅឆ្នាំចាស់ និងបង្ហាញតារាងប្រចាំឆ្នាំ
- របៀបធ្វើរបាយការណ៍ និងរៀបចំប្រព័ន្ធគណនេយ្យឲ្យស្របតាមស្តង់ដាដើម្បីងាយស្រួលក្នុងការធ្វើរបាយការណ៍
- ការធ្វើលិខិតលេខពី ក្រុមប្រឹក្សាគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ការចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដា
- ពិនិត្យឡើងវិញលើតារាងគំនូសតាងនៃអង្គការខ្លួនដើម្បីងាយស្រួលនៅពេលយើងត្រូវការបង្កើតរបាយការណ៍សម្រាប់ក្រុមប្រឹក្សាគណនេយ្យជាតិ

▶ ***ចំណុចសំខាន់ៗដែលសិក្ខាកាមនឹងចែករំលែកបន្តទៅអ្នកផ្សេងទៀត***

- ពន្ធកាត់ទុក (ពន្ធលើសេវាកម្ម ពន្ធអចលនទ្រព្យ ពន្ធ FiH7xtem in bank)
- របៀប បង្ហាញពីកំហុសឆ្គង ឬការកែតម្រូវ ទៅលើរបាយការណ៍ឆ្នាំមុន
- ច្បាប់ និងក្របខណ្ឌច្បាប់ដែលតម្រូវក្នុងការដាក់ជូនរបាយការណ៍ទៅក្រុមប្រឹក្សាគណនេយ្យនៃក្រសួងហិរញ្ញវត្ថុនិងសេដ្ឋកិច្ច
- ចំណេះដឹងពីការបំពេញទម្រង់របាយការណ៍ហិរញ្ញវត្ថុ និងទម្រង់របាយការណ៍ហិរញ្ញវត្ថុ
- ពត៌មានអំពីច្បាប់ស្តីពីការអនុវត្តន៍ច្បាប់ក្រុមប្រឹក្សាគណនេយ្យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចំណុចខ្លះពីក្របខណ្ឌអនុវត្តន៍ស្តង់ដាហិរញ្ញវត្ថុ
- មិនទាន់ច្បាស់មិនហ៊ានចែកអ្នកដទៃទេ
- យល់គ្រប់មេរៀនទាំងអស់ ហើយនឹងចែករំលែកបន្ត
- របាយការណ៍ និងការកត់ត្រាជាភាសាខ្មែរ និងលុយរៀល
- ចំណុចទាក់ទងនឹងបទដ្ឋានគណនេយ្យ Accrual Based & Cash Basis & Cash modified
- ការស្នើរសុំលេខអត្តសញ្ញាណកម្មក្រុមហ៊ុនសវកម្មមិនឲ្យលើស ៥ឆ្នាំ

- អំពីតួនាទីរបស់កម្មវិធីត្រូវដាក់លាក់ដោយកំណត់នូវសកម្មភាពការងារឲ្យច្បាស់លាស់ដើម្បីងាយស្រួលក្នុងការបំពេញទម្រង់របាយការណ៍
- ការដាក់របាយការណ៍ លក្ខខណ្ឌសវនករ និងសមាសភាពក្រុមប្រឹក្សាជាតិគណនេយ្យ

▶ ***យោបល់និងសំណូមពរពីសិក្ខាកាមសម្រាប់ធ្វើឲ្យវេទិការៀនសូត្របន្តកាន់តែមានភាពប្រសើរឡើង***

- សូមឲ្យមានវគ្គបណ្តុះបណ្តាល នេះបំពេញបន្ថែមទៀតព្រមទាំងបញ្ជាក់ពីចំណុចសំខាន់ៗដោយមានការអនុវត្តន៍ផ្ទាល់ផង
- សម្រាប់ពេលក្រោយទៀតសូមឲ្យមានការពន្យល់ឲ្យបានក្បោះក្បាយនិងយឺតជាងនេះ និងមានរយៈពេលច្រើនជាងនេះ (មិនទាន់យល់ច្បាស់ឡើយ)
- សូមឲ្យ CCC ជួយបន្តផ្តល់ពត៌មានដល់អង្គភាពផ្សេងទៀតដែលមិនបានដឹងពីរដ្ឋាភិបាល និងផ្តល់ជាវេទិកាបន្តទៀតដល់អង្គការ
- ប្រសិនបើពេលបំពេញលើរបាយការណ៍នៅចុងឆ្នាំតើយើងអាចទំនាក់ទំនងទៅអ្នកណាពេលយើងមានចម្ងល់ ឬមិនទាន់ច្បាស់លើទម្រង់របាយការណ៍
- សូមឲ្យ CCC ជួយបង្កើតក្រុមធ្វើរបាយការណ៍ហិរញ្ញវត្ថុទៅតាមអង្គការសមាជិកនីមួយៗផង
- មិនទាន់យល់ទាក់ទងនឹង Grant Income(ផ្តល់មូនិធិខ្នាតតូច)
- គួរតែផ្តល់ចម្លើយទៅសិក្ខាកាមដែលពួកគាត់បានសួរទៅតាម Email etc…,
- សូមឲ្យមានវគ្គនេះទៀតដើម្បីឲ្យកាន់តែច្បាស់ទាក់ទងនឹង Finance Report
- សូមឲ្យមានវគ្គផ្សេងៗដូចគ្នានេះនៅពេលក្រោយទៀត
- ដោយសារជាលើកដំបូងសម្រាប់ខ្ញុំ ដែលបានចូលរួម និងបានដឹង វាពិបាកបន្តិច តែប្រធានបទល្អ
- សំណួររបស់អ្នកចូលរួមទទួលបានចម្លើយទៅតាមសំណួររបស់អ្នកសួរ
- ចំណុចមួយដែលវាគ្មិនបានចែករំលែក តែនៅមានចំណុចជាច្រើនដែលត្រូវការពេលវេលាដើម្បីរៀនសូត្រ និងអនុវត្តន៍
- សូមឲ្យចេញលិខិតកូដរបស់អង្គការចេញពីក្រសួង
- អ្នកចូលរួមច្រើនពេក គួរបំបែកក្រុមជា 2 ឬ3ក្រុម

## សេចក្តីសន្និដ្ឋាន

យោងតាមលទ្ធផលនៃការវាយតម្លៃនៃវេទិកាសិក្សារៀនសូត្រនេះបានបង្ហាញថា ជារួមសិក្ខាកាមទាំងអស់មានការចាប់អារម្មណ៍និងពេញចិត្តចំពោះវេទិកាសិក្សារៀនសូត្រនេះ រួមទាំងទីកន្លែង ការផ្តល់ភស្តុភា ជាពិសេសពួកគេពេញចិត្តនូវវិធីសាស្ត្រ និងការចែករំលែកបទពិសោធន៍របស់វាគ្មិនដែលបានពន្យល់នូវខ្លឹមសារមេរៀនបានច្បាស់លាស់ និងបានជួយដោះស្រាយនូវបញ្ហាប្រឈមមួយចំនួនដែលទាក់ទងក្នុងការអនុវត្តច្បាប់ពន្ធដារនៅក្នុងអង្គការរបស់ពួកគេ។ សិក្ខាកាមយល់កាន់តែច្បាស់នូវច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងក្របខ័ណ្ឌនៃស្តង់ដានៃការអនុវត្តស្តង់ដារបាការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញដែលត្រូវអនុវត្តនៅក្នុងអង្គការរបស់ពួកគេ ។ ជាងនេះទៀតនោះ សិក្ខាកាមទាំងនោះក៏មានការតាំងចិត្តយកចំណេះដឹងនេះទៅចែករំលែកដល់បុគ្គលិករបស់ខ្លួន និងអនុវត្តន៍នៅក្នុងអង្គការឲ្យកាន់តែប្រសើរឡើងផងដែរ។

លើសពីនេះទៅទៀត ដោយមានការចាប់អារម្មណ៍ខ្លាំងទៅលើប្រធានបទនិងវាគ្មិន ហើយនឹងមានរយៈពេលខ្លីផងនោះ សិក្ខាកាមទាំងអស់បានលើកសំណើនិងសំណូមពរដល់អង្គការ គសក ឲ្យរៀបចំវេទិកានេះម្តងទៀត ដើម្បីឲ្យពួកគេមានឪកាសជួបជាមួយវាគ្មិនបានជួយពន្យល់លំអិតបន្ថែមទៀតដែលទាក់ទងនឹងការ

អនុវត្តទៅលើការបំពេញទម្រង់របាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ។

## មតិបិទកម្មវិធីវេទិកាសិក្សារៀនសូត្រដោយ លោ យន ប៊ុនថុង ប្រធានប្រតិបត្តិនៃអង្គការ គសក

នៅចុងកម្មវិធីនៃវេទិកាសិក្សារៀនសូត្រនេះ លោក **យន ប៊ុនថុង** ប្រធានប្រតិបត្តិនៃអង្គការ គសក បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ លោក សេង តុលា លោក យ៉ាង ជីញលីង និងលោក ហ៊ាង វណ្ណថា តំណាងមកពី ក.ជ.គ និងអង្គសិក្ខាកាមទាំងអស់ដែលបានចំណាយពេលវេលាក្នុងការចូលរួម និងយកចិត្តទុកដាក់រៀនសូត្រពេញមួយថ្ងៃ។ ជាងនេះទៅទៀតលោកសូមថ្លែអំណរគុណជាពិសេសដល់ លោកសេង តុលា ដែលបានលះបង់ពេលវេលាដ៏មមារញឹករបស់លោក ដើម្បីចែករំលែកនូវចំណេះដឹងទាក់ទងទៅនឹងវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា និងក្របខ័ណ្ឌនៃការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ សំដៅធ្វើយ៉ាងណាឲ្យអង្គភាពមិនស្វែងរកប្រាក់ចំណេញ បានយល់ដឹងនិងអនុវត្តន៍បានត្រឹមត្រូវក្នុងការបំពេញទម្រង់របាយការណ៍ឲ្យកាន់តែមានភាពប្រសើរឡើង។

លោក យន ប៊ុនថុង បានបន្តថា ទាក់ទងទៅនឹងវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា និងក្របខ័ណ្ឌនៃការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញនេះ គឺជាកាតព្វកិច្ចរបស់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដូច្នេះអង្គការត្រូវតែចាប់ផ្តើមអនុវត្តន៍ចាប់ពីពេលនេះតទៅ និង បន្តការសិក្សារៀនសូត្របន្ថែមទៀត។

# ឧបសម្ព័ន្ធៈ កម្មវិធីលម្អិត និងករណីសិក្សា

# ឯកសារទស្សនៈទាន

# វេទិកាសិក្សារៀនសូត្រការគ្រប់គ្រងហិរញ្ញវត្ថុលើកទី២២

## ស្តីពី

## "ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ"

ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង៨: 00នាទី ព្រឹកដល់ម៉ោង៥:០០នាទីរសៀល

នៅដាយកូនៀសិនធើ ផ្ទះលេខ១៩-២១ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

## I.សេចក្តីផ្តើម

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាហៅកាត់ថា គ).ស.កគឺជាអង្គការសមាជិកភាពដែលបាន ( បង្កើតឡើងដំបូងគេបង្អស់នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៩០ដោយបានដើរតួនាទីចំបងក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ វិជ្ជាជីវៈ គណនេយ្យភាព តម្លាភាព អភិបាលកិច្ច និងការអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាពចំពោះអង្គការសង្គមស៊ីវិលដែលកំពុងប្រតិបត្តិការវិស័យផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជា។

នៅក្នុងដំណាក់កាលទី៣នៃផែនការកម្មវិធីរបស់អង្គការ គ.ស.ក សម្រាប់រយៈពេលប្រាំឆ្នាំ២០១៧ដល់ ២០២១។ គោលដៅអង្គការគ.ស.កគឺជាអង្គការសង្គមស៊ីវិលមួយដែលមានកិច្ចសហការដ៏រឹងមាំនិងមាន សមត្ថភាពឆ្លើយតបទៅនឹងបញ្ហានៃការអភិវឌ្ឍនៅកម្ពុជា។ គោលដៅផែនការកម្មវិធីគឺៈ ១បង្កើនប្រសិទ្ធភាព ( និងផលប៉ះពាល់នៃអង្គការសង្គមស៊ីវិល និង ២ធ្វើឲ្យប្រសើរឡើងនូវបរិយាកាសអំណោយផលសម្រាប់អង្គ( ការសង្គមស៊ីវិល។ ដើម្បីឆ្លើយតបទៅនឹងគោលដៅរបស់ខ្លួនអង្គការ គ.ស.ក បានរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាព និងឪកាសសិក្សារៀនសូត្រសម្រាប់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ដើម្បីមានឥទ្ធិពលដល់ការគិត និងការអនុវត្តន៍របស់ពួកគេ និងដើម្បីផ្តល់សេវាកម្មដែលមានគុណភាពខ្ពស់សមស្របក្នុងការឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃអង្គការសង្គមស៊ីវិលទាំងនោះ។

យុទ្ធសាស្រ្តមួយក្នុងចំណោមយុទ្ធសាស្រ្តទាំងប្រាំពីរគឺ ការសិក្សារៀនសូត្រនិងអភិវឌ្ឍន៍សមត្ថភាពសម្រាប់សមាជិករបស់អង្គការគសក និងអង្គការសង្គមស៊ីវិលផ្សេងៗទៀតដែលបានចាប់អារម្មណ៍។ ក្នុងចំណោមកម្មវិធីនេះគឺ វេទិកាសិក្សារៀនសូត្រអំពី ការគ្រប់គ្រងធនធានមនុស្ស ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ព័ត៌មានទំនាក់ទំនងបច្ចេកវិទ្យា និង ការគ្រប់គ្រងហិរញ្ញវត្ថុ ។ វេទិកាសិក្សារៀនសូត្រនេះមានសារៈសំខាន់ណាស់ក្នុងការកសាងសមត្ថភាពសមាជិករបស់ខ្លួនដើម្បីឲ្យការអនុវត្តន៍ផ្តល់សេវាកម្មរបស់ពួកគេកាន់តែប្រសើរឡើង។

ដើម្បីធានាបាននូវគុណភាពនៃវេទិកាសិក្សារៀនសូត្រនេះ អង្គការគសកបានបង្កើតក្រុមការងារដើម្បីជួយផ្តល់ការពិភាក្សានិងយោបល់សម្រាប់ការសិក្សារៀនសូត្ររបស់អង្គការសហគមន៍នៅក្នុងប្រទេសកម្ពុជា។

ក្រុមការងារនេះបានដើរតួនាទីគណៈកម្មការទទួលខុសត្រូវរួមដើម្បីផ្តល់ជាយុទ្ធសាស្ត្រ និងបច្ចេកទេសគាំទ្រដល់អង្គការសហគមន៍ក្នុងការលើកកំពស់និងធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងធនធានមនុស្ស ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ព័ត៌មានទំនាក់ទំនងបច្ចេកវិទ្យា និង ការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងអង្គការរបស់ពួកគេសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលក្នុងវិស័យអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា។

ដើម្បីបន្តការឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់អង្គការសហគមន៍និងពង្រឹងសមត្ថភាពបន្ថែមអំពីអភិបាលកិច្ចល្អនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា អង្គការគសកនឹងត្រូវបានអនុវត្តបន្តវេទិកាសិក្សារៀនសូត្រលើកទី២២នៃការគ្រប់គ្រងហិរញ្ញវត្ថុដោយផ្អែកលើប្រធានបទដែលបានជ្រើសរើសដោយក្រុមការងារនិងលើកឡើងដោយអង្គការសិក្ខាកាមដែលបានចូលរួមក្នុងវេទិកាសិក្សារៀនសូត្រកាលពីឆ្នាំកន្លងទៅគឺ *"ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ "*។

វេទិកាសិក្សារៀនសូត្រលើកទី២២នៃការគ្រប់គ្រងហិរញ្ញវត្ថុគឺត្រូវបានកំណត់អ្នកចូលរួមជំនាញផ្នែកហិរញ្ញវត្ថុដែលអញ្ជើញមកពីអង្គការសមាជិក និងមិនមែនសមាជិករបស់អង្គការគសក។ វេទិកានេះនិងប្រារព្ធឡើងពេញមួយថ្ងៃនៅថ្ងៃទី១៥ខែសីហាឆ្នាំ២០១៨ នៅអាគារដាយកូនៀសិនធើ ដែលមានគោលបំណងជាក់លាក់ លទ្ធផលរំពឹងទុករយៈពេលមធ្យម និងកម្មវិធីលំអិតដូចខាងក្រោមនេះ៖

## II. កាលបរិច្ឆេទនិងទីកន្លែងនៃវេទិកាសិក្សារៀនសូត្រ

វេទិកានេះនឹងប្រារព្ធធ្វើឡើងពេញមួយថ្ងៃនៅថ្ងៃទី**១៥ ខែ សីហា ឆ្នាំ ២០១៨ វេលាម៉ោង៨: 00នាទី ព្រឹក ដល់ម៉ោង៥:០០នាទី**រសៀលនៅដាយកូនៀសិនធើ ផ្ទះលេខ១៩-២១ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។

## III. គោលបំណងនៃវេទិកាសិក្សារៀនសូត្រ

- ដើម្បីជួយពង្រឹងសិក្ខាកាមបានយល់ច្បាស់អំពីច្បាប់ស្តីពី គណនេយ្យ និងសវនកម្ម សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញនិង
- ដើម្បីជួយសិក្ខាកាមយល់ច្បាស់អំពីរបៀបនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុវត្តន៍តាម **"ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ"**
- ដើម្បីបង្កើតបរិយាកាសវេទិការៀនសូត្រនិងចែករំលែកក៏ដូចជាកសាងបណ្តាញឲ្យកាន់តែ មានភាពរឹងមាំក្នុងចំណោមអង្គការសង្គមស៊ីវិលនិងការទំនាក់ទំនងជាមួយមន្ត្រីពាក់ព័ន្ធឲ្យកាន់តែមានប្រសិទ្ធភាព

## IV. សិក្ខាកាមគោលដៅ

វេទិកាសិក្សារៀនសូត្រនេះនឹងផ្តល់ជូនសិក្ខាកាមអបប្បរមា៨០ទៅ១០០នាក់ដែលអញ្ជើញមកពីសមាជិកនិងមិនមែនជាសមាជិករបស់អង្គការគសកដែលមានវិជ្ជាជីវៈផ្នែកហិរញ្ញវត្ថុ។ សិក្ខាកាមម្នាក់ៗគួរត្រូវបានកំណត់កម្រិតបុគ្គលិកថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងថ្នាក់គ្រប់គ្រងកណ្តាលរបស់អង្គការ ហើយពួកគេនឹងមានការប្តេជ្ញាចិត្តយកទៅអនុវត្តនូវអ្វីដែលបានរៀននៅក្នុងអង្គការរបស់ពួកគេ។

សូមស្វាគមន៍សិក្ខាកាមដែលអញ្ជើញមកពីអង្គការមិនមែនសមាជិករបស់អង្គការគសក ប៉ុន្តែតម្រូវឲ្យចូលរួមបង់វិភាគទានទៅតាមគោលការណ៍ដែលបានចែងនៅក្នុងគោលនយោបាយសេវាកម្មអភិវឌ្ឍសមត្ថភាព

ដើម្បីយកទៅជួយគាំទ្រផ្នែករៀបចំភស្តុភា។

## VI. កម្មវិធីលម្អិត

| ពេលវេលា | មាតិកាសំខាន់ៗ | រាគ្គិនដោយ |
|---|---|---|
| 07:30-08:20 | ភ្ញៀវអញ្ជើញមកដល់ និងចុះបញ្ជីវត្តមាន | • **អ្នកស្រី ស្រេង សោភ័ណលក្ខិណា** ជំនួយការផ្នែកកម្មវិធី អង្គការគសក |
| 08:20-08:30 | គោរពទង់ជាតិ | • **អង្គសិក្ខាកាម** |
| | កិច្ចស្វាគមន៍<br>ការណែនាំអំពីគោលបំណងនៃវេទិកាសិក្សារៀនសូត្រ និងការប្រកាសជូនដំណឹងទូទៅ | • **អ្នកស្រី កែវ ម៉ារ៉ា** អ្នកឯកទេសផ្នែកសិក្សារៀនសូត្រ អង្គការ គសក |
| 08:30-08:40 | កិច្ចស្វាគមន៍ និង សន្ទរកថាបើកកម្មវិធី | • **លោក សៀង សារឿន** នាយកប្រតិបត្តិការ អង្គការ គសក |
| 08:40-09:15 | **<u>វគ្គទី១:</u> រំលឹកមេរៀនឡើងវិញស្តីពី**<br>• **"ការអនុវត្តច្បាប់និងពន្ធដារ" នៃប្រទេសកម្ពុជា**<br>• **ករណីសិក្សាស្តីពី ការផ្លាស់ប្តូរជាវិជ្ជមាន ក្នុងការគ្រប់គ្រងលទ្ធកម្ម ក្រោយពេលចូលរួមវេទិកាសិក្សារៀនសូត្រ** | • **លោក មាស យាង** ប្រធានផ្នែកប្រតិបត្តិ CCIM<br>• **អ្នកស្រី កុល សុភាព** ប្រធានគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋបាល Live and Learn Cambodia |
| 9:15:- 09:30 | សម្រាកពិសារអាហារសម្រន់ | អង្គសិក្ខាកាម |
| 09:30-12:00 | **<u>វគ្គទី២:</u>** បទបង្ហាញអំពី **ច្បាប់ស្តីពី**<br>***"គណនេយ្យ និង សវនកម្ម"***<br><br>**<u>សំនួរ និងចម្លើយ</u>** | • **លោក សេង តុលា** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ<br>• **លោក យ៉ាង ជីងលីង** មន្ត្រី នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា ជាតិគណនេយ្យ<br>• **លោក ហ៊ាង វណ្ណថា** មន្ត្រី នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា ជាតិគណនេយ្យ<br>• **អង្គសិក្ខាកាម** |
| 12:00-01:30 | សម្រាកពិសារអាហារសាមគ្គី | • **អង្គសិក្ខាកាម** |
| 01:30-01:35 | ល្បែងថាមពល | • **អង្គសិក្ខាកាម** |

| | | |
|---|---|---|
| 01:35-03:15 | <u>វគ្គទី៣:</u> បទបង្ហាញ ស្តីពី<br>"ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ"<br><br><u>សំនួរ និងចម្លើយ</u> | • **លោក សេង តុលា** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ<br>• **លោក យ៉ាង ដឹងលីង** មន្ត្រី នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា ជាតិគណនេយ្យ<br>• **លោក ហ៊ាង វណ្ណថា** មន្ត្រី នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា ជាតិគណនេយ្យ<br>• **អង្គសិក្ខាកាម** |
| 3:15-3:30 | សម្រាកពិសារអាហារសម្រន់ | • **អង្គសិក្ខាកាម** |
| 3:30-4:20 | <u>វគ្គទី៣: បទបង្ហាញបន្ត ស្តីពី</u><br>"ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ"<br>និង<br>ការអនុវត្តផ្ទាល់របស់សិក្ខាកាមអំពីរបៀបបំពេញទម្រង់របាយការណ៍ហិរញ្ញវត្ថុ<br><br><u>សំនួរ និងចម្លើយ</u> | • **លោក សេង តុលា** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ<br>• **លោក យ៉ាង ដឹងលីង** មន្ត្រី នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា ជាតិគណនេយ្យ<br>• **លោក ហ៊ាង វណ្ណថា** មន្ត្រី នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា ជាតិគណនេយ្យ<br>• **អង្គសិក្ខាកាម** |
| 4:20-4:50 | <u>វគ្គទី៤:</u><br>• **មតិនិងចំណាប់អារម្មណ៍របស់សិក្ខកាម**<br>• ផែនការបន្ទាប់<br>• ការពិភាក្សាជ្រើសរើសប្រធានបទសម្រាប់វគ្គបន្ទាប់<br>• ការវាយតម្លៃបញ្ចប់វគ្គ | • **អ្នកស្រី កែវ ម៉ារ៉ា** អ្នកឯកទេសផ្នែកសិក្សារៀនសូត្រ អង្គការ គសក<br>• **អង្គសិក្ខាកាម** |
| 4:50-5:00 | **សេចក្តីសន្និដ្ឋានរួមនិងមតិបិទកម្មវិធី** | • **លោក យន ប៊ុនថុង** ប្រធានផ្នែកប្រតិបត្តិការ អង្គការគសក |

<u>សំគាល់:</u> **អង្គការគសកសូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធីដោយផ្អែកលើលទ្ធភាពរបស់វាគ្មិននិងបញ្ហាពេលវាលា ក្នុងករណីចាំបាច់។**

# The Best Practices of the Financial Management Learning Forum Case study of Live & Learn Cambodia

***Ms. Kol Sopheap is a Finance and Admin Manager***.

Kol Sopheap has worked for Live & Learn Cambodia for four years as Finance and Administration Manager. She has actively engaged in Financial Management Learning Forum and become a role model within the organisation and in the forum, while she had made a lot of progress and contributed to policy development within her Organisation.



***Ms. Kol Sopheap, Finance and Admin Manager***
**Live & Learn Cambodia**

While Live & Learn Cambodia has been improving its policies and internal practices to ensure better governance and management practice, transparency and accountability, her knowledge and contribution become significant. Several policies, guidelines and procedures were jointly reviewed and updated by staff.

She was mainly assigned to review Financial Management Policy and Procurement Policy. Based on knowledge she learnt through the Forum, the ideas she has proposed during the reviews were accepted. "*What I mainly learnt is Procurement Management; our previous procurement policy was very broad, and without clear procedures, we found ourselves very hard to implement*," said Sopheap. She added that, *"While we faced human resource challenges, it was even more difficult for us to deal with the existing policies and staff have been worked overload."* This policy is improved while she has attended within Financial Management Learning Forum, organised by CCC. She learnt a lot of practical experiences from the participants and guest speakers of each learning forum, especially she learnt about the **"Procurement Management"**. Through this forum, she reflected to her procurement policy and she knew and clearly understood on the gaps in this policy, and finally brought these attentions to her management team. As the result the procurement policy was updated and approved by the Board of Governance. This policy is now providing clear instructions on processes so as easy to understand by all staff, particularly the amounts for different types of procurement and staff involvement in each step.




Through this engagement and also having opportunities to apply the knowledge, she revealed that it is important to have opportunities to learn new knowledge, share with colleagues and reflect of what have been learnt in real life. "*I am confident that my skill and knowledge have improved as I keep learning and sharing, not only Financial Management, Employee Relations, but many more, through the Forum and the Forum is an important platform for CSOs,*" she added. She also emphasized that, it is the first ever initiative or platform, where NGOs staff could learn and share practical knowledge and experience and encourage everyone to join and support. She has brought to attention that CCC, with continuous support of its donors, should keep supporting NGO members and partners in order to effectively respond to the challenges relating to capacity building and performance improvement, using such learning forum.